ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០-សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ មួយ.**

ត្រូវបានកែសម្រួលប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់។

**ប្រការ ១ ថ្មី.**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដែលមានឈ្មោះ “ គណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និង កាត់បន្ថយការប្រើប្រាស់ថ្នាំជក់ ” ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសុខាភិបាល | | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | | អនុប្រធាន |
| ៤. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| ៥. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងពាណិជ្ជកម្ម | ០១រូប | សមាជិក |
| ៦. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| ៧. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| ៨. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| ៩. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| ១០. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងអប់រំយុវជន និងកីឡា | ០១រូប | សមាជិក |
| ១១. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងធម្មការ និងសាសនា | ០១រូប | សមាជិក |
| ១២. អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន | ០១រូប | សមាជិក |
| ១៣. នាយកខុទ្ទកាល័យក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| ១៤. ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព | ០១រូប | សមាជិក |

**ប្រការ ពីរ.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ បី.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ បី
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា